# អំពីអង្គការសីលការ និង ធនធានមនុស្ស

## សីលការ

**សីលការ** ជាអង្គការ កសាងសមត្ថភាពក្នុងស្រុកមួយ ដែលមិនប្រកាន់បក្សនយោបាយ មិនប្រកាន់ពូជសាសន៍ និងមានមូលដ្ឋាននៅភ្នំពេញ។ អង្គការសីលការធ្វើការងារដើម្បីពង្រឹងសមត្ថភាព ស្ថាប័នសាធារណ ឯកជន និងរដ្ឋាភិបាល តាមរយៈការផ្សារភ្ជាប់ ការអប់រំ និងការហ្វឹកហ្វឺន ពីទស្សនទាន និងជំនាញស្នូល (មានរដ្ឋបាល គ្រប់គ្រង និងហិរញ្ញកិច្ច) ព្រមទាំងចូលរួម វីអភិវឌ្ឍន៍ និងអនុវត្តិកម្មវិធីដើម្បីជំរុញ ការជឿនលឿន នៃអង្គការ និងស្ថាប័ន ឱ្យមានតម្លាភាព និងគណនេយ្យភាពរបស់គេ។ អង្គការសីលការធ្វើការងារ ក្នុងផ្នែកសន្តិភាព និងការផ្សះផ្សារជាតិ ដែលជាជំហានមូលដ្ឋាន ដើម្បីបង្កើតឱ្យមានបរិដ្ឋានសមស្រប សំរាប់សន្តិសុខ និងការអភិវឌ្ឍមនុស្ស ឱ្យកើតឡើងទៅបាន។

## ទស្សនវិស័យ បញ្ញត្តិ របស់សីលការ

ប្រជាពលរដ្ឋខ្មែរ រស់នៅក្នុងសង្គម សេដ្ឋកិច្ចមួយដែល អភិវឌ្ឍ ប្រកាន់យកពហុនិយម និងដែលផ្តល់គុណតម្លៃ ដល់ការរៀនសូត្របើកចំហ ការគោរពសិទ្ធមនុស្ស សមភាពយេនឌ័រ និងពឹងលើខ្លួនឯង។

## សីលការ មានបេសកម្មដូចតទៅនេះ

- បណ្តុះបណ្តាលខ្មែរ ឱ្យគេកសាង រៀបចំ អភិវឌ្ឍ ពង្រឹងអង្គការ និងស្ថាប័នរបស់គេ។
- ធ្វើការដោយសកម្មជាមួយ បុគ្គល អង្គការ និងស្ថាប័នដើម្បីលើកកំពស់ សមភាពយេនឌ័រក្នុងការកសាងសង្គមខ្មែរ។
- ធ្វើវិភាគទានទៅលើការកសាងសន្តិភាពនៅកម្ពុជា ការដោះស្រាយទំនាស់ដោយស្ថាបនា ការដោះស្រាយបញ្ហា ប្រកបដោយប្រសិទ្ធភាព និងសមភាពយេនឌ័រ។

## លោកស្រី ធីដា ឃឹះ

ជានាយិការប្រតិបត្តិ/អ្នកសំរបសំរួល/អ្នកផ្តល់ប្រឹក្សា ដែលមានបទពិសោធន៍ជាង ៣០ ឆ្នាំ លើការងារគ្រប់គ្រង និងអភិវឌ្ឍន៍អង្គការ និងស្ថាប័ននានានៅកម្ពុជា និងនៅសហរដ្ឋអាមេរិក។ ក្នុងកំលុងពេលដែល លោកស្រីផ្តល់

សេវានៅ ទីក្រុងសាន់អន់តូនីអូ និងវ៉ាស៊ីនតោន នៅសហរដ្ឋអាមេរិក លោកស្រីទទួលបានរង្វាន់ស្នាដៃជាច្រើន ខាងផ្តល់សេវាឆ្នើមដល់សហគមន៍ និងខាងការងារគ្រប់គ្រងល្អលើធនធានអ្នកស្ម័គ្រចិត្ត ពីនាយកដ្ឋានធនធានមនុស្សនៃរដ្ឋតិកសាស ព្រមទាំងពីសមាគមន៍ថ្នាក់ជាតិដើម្បីអភិវឌ្ឍន៍ការអប់រំ សម្រាប់សញ្ជាតិអាមេរិកកាំងជាតិដើមជាកម្ពុជា ឡាវ និងវៀតណាម និងពីសមាគមខ្មែរនៅស៊ីកាគោ។ លោកស្រីជាស្ថាបនិក និងបានបន្តដឹកនាំក្រុមជាវិជ្ជាជីវៈនៃអង្គការសីលការ ដើម្បីអនុវត្តយុទ្ធសាស្រ្តច្នៃប្រឌិតថ្មី និងផ្តល់សេវាដល់ដៃគូរនៅក្នុងរដ្ឋាភិបាល និងស្ថាប័ននានានៅកម្ពុជា។ លោកស្រីមានមុខងារនៅក្នុងគណៈកម្មាធិការប្រតិបត្តិអន្តរជាតិដើម្បីឃ្លាំមើលសង្គម និងគណៈកម្មាធិការប្រតិបត្តិ របស់អង្គការអន្តរជាតិឃ្លាំមើល ការគោរពសិទ្ធមនុស្ស និងអង្គការសង្គមស៊ីវិលរបស់ប្រទេសមិនទាន់មានការអភិវឌ្ឍ។ ចាប់ពីឆ្នាំ២០០៦មក លោកស្រីបានក្លាយជាអគ្គលេខាធិការ នៃគណៈកម្មាធិការ លើកស្ទួយស្រ្តីក្នុងវិស័យនយោបាយនៅកម្ពុជា ដើម្បីតស៊ូមតិឱ្យស្រ្តីបានចូលរួមដោយ ស្មើភាពក្នុងដំណើរការអភិវឌ្ឍន៍ និងការធ្វើសេចក្តីសំរេចចិត្តស្របតាម "អនុសញ្ញាស្តីពីការលប់បំបាត់រាល់ ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ" ហៅកាត់ថា ស៊ី-ដ និងតាមរយៈគោលដៅអភិវឌ្ឍន៍សហស្សវត្ស។

## លោក ហេង វណ្ណារិទ្ធិ

លោក ហេង វណ្ណារិទ្ធិ បានចាប់ផ្តើមជាមួយអង្គការសីលការតាំងពីឆ្នាំ ១៩៩៧។ ពីមុនមកលោកមានបទពិសោធន៏ជាច្រើនឆ្នាំ ជាប្រធាននៃអនុមន្ទីរបណ្តុះបណ្តាល នៅកាកបាទក្រហមកម្ពុជា។ ហើយមុននោះទៀត លោកជាសាស្រ្តាចារ្យគណិតវិទ្យានៅវិទ្យាល័យអស់រយៈពេល៦ឆ្នាំ។ លោកវណ្ណារិទ្ធិ មានបទពិសោធន៏បណ្តុះ បណ្តាលមនុស្សពេញវ័យយ៉ាងទូលំទូលាយ ហើយលោកក៏មានភារៈកិច្ច សម្របសម្រួលកិច្ច សហការជាមួយគ្រូ នានាក្នុងការអភិវឌ្ឍកម្មវិធីសិក្សា និងផ្តល់ការកសាងសមត្ថភាពតាមតំរូវការរបស់អតិថិជន។ លោកក៏ជា គ្រូឈានមុខមួយរូបដែរលើជំនាញតស៊ូមតិក៏រិតស៊ីជំរៅ ដែលរួមទាំងជំនាញស្រាវជ្រាវដោយមានការចូលរួម និងយុទ្ធសាស្រ្តតស៊ូមតិ។ លោកក៏ជាអ្នកសម្របសម្រួលដំណើរការកសាងផែនការ និងការធ្វើផែនការ យុទ្ធសាស្រ្តរបស់ស្ថាប័នផងដែរ។ លោក វណ្ណារិទ្ធិ បានបញ្ចប់បរិញ្ញាបត្រផ្នែកគណិតវិទ្យា ហើយទទួលការបណ្តុះបណ្តាលលើជំនាញស្រាវជ្រាវដោយមានការចូលរួម នៅឥណ្ឌូនេស៊ី និងលើយុទ្ធសាស្រ្តតស៊ូមតិ នៅប្រទេសហ្វីលីពីន។

## លោក អ៊ុក ចាន់វិទ្ធី

លោក អ៊ុក ចាន់វិទ្ធី ជាសាស្រ្តាចារ្យឈានមុខនៅអង្គការសីលការតាំងពីឆ្នាំ ២០០០មក។ លោកបាននាំយកនូវគំនិតពីបទពិសោធន៍ ក្នុងផ្លូវអាជីវកម្មឯកជន មកអង្គការសីលការ។ លោកបានបញ្ចប់បរិញ្ញាបត្រផ្នែក

គ្រប់គ្រងអាជីវកម្ម ហើយបានបន្តការបណ្តុះបណ្តាលនៅសកលវិទ្យាល័យហាណូយ ក្រោមកម្មវិធី MPDF ឆ្នាំ២០០១ លើមុខវិជ្ជាជំនាញអាជីវកម្ម និងវិធីសាស្ត្របណ្តុះបណ្តាល។ លោកក៏បានទទួលការ បណ្តុះបណ្តាលផ្ទាល់លើវិធីសាស្ត្របណ្តុះបណ្តាលទំនើបបែបអក្សរ ធី (T) ជាមួយក្រុមសាស្ត្រាចារ្យអន្តរជាតិនៅប្រទេសថៃ។ លោកចាន់វុទ្ធី ជាគ្រូបង្គោល វគ្គបណ្តុះបណ្តាលគ្រូបង្គោល (TOT) វគ្គរៀបចំតាក់តែង និងគ្រប់គ្រងគំរោង វគ្គអភិវឌ្ឍន៍គំរោងសំណើរ វគ្គតាមដាននិងវាយតំលៃហិរញ្ញវត្ថុ និងវគ្គជំនាញទីផ្សារ។ លោកអភិវឌ្ឍកម្មវិធីសិក្សាទៅតាមជាក់ស្តែង ស៊ីជំរៅលើផ្នែកជំនាញរបស់ខ្លួន។

## លោក សាក់ សុធា

លោក សាក់ សុធា គឺជាគ្រូបណ្តុះបណ្តាលដ៏មានបទពិសោធន៍ ក្នុងផ្នែកកសាងសន្តិភាព និងដោះស្រាយទំនាស់។ លោកចូលរួមជាមួយសីលការនៅ ឆ្នាំ ២០០៣ ដោយធ្វើការដើម្បីដោះស្រាយទំនាស់/កម្មវិធីប្រឹក្សា ក្នុងមុខងារជាជំនួយការកម្មវិធីផង ជាគ្រូបណ្តុះបណ្តាលផង។ លោកបានប្រឡូកក្នុងសេវាកម្មប្រឹក្សាដល់ JICA ADB UNIFEM UNESCAP ជាអ្នករៀបចំកម្មវិធីពិសេស។ លោកមានបទពិសោធន៍ផ្តល់ការបណ្តុះ បណ្តាលជំនាញគ្រឹះក្នុងការដឹកនាំ ការធ្វើសេចក្តីសម្រេចចិត្ត ការសម្របសម្រួល និងការកត់ត្រាកំណត់ហេតុ ដល់សមាជិកគណៈកម្មាធិការមូលដ្ឋានក្នុងដៃគូរបស់សីលការជាមួយអង្គការឃែរ កម្ពុជា (Care Cambodia) នៅខេត្តព្រៃវែង។ លោកបញ្ចប់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រនយោបាយ នៅសកលវិទ្យាល័យ Gadjah Mada នៅឯ Yogyakarta ប្រទេសឥណ្ឌូនេស៊ី និងសញ្ញាបត្របរិញ្ញាបត្រផ្នែកប្រវត្តិវិទ្យា នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ កម្ពុជា។ លោកមានជំនាញការក្នុងផ្នែកយែនឌ័រ និង ការផ្តល់អំណាចដល់ស្ត្រី តាមរយៈការចូលរួមក្នុងវិស័យនយោបាយផងដែរ។

## លោកស្រី ហុង សុវណ្ណនី

លោកស្រី ហុង សុវណ្ណនី ជាសាស្ត្រាចារ្យផ្នែកទំនាក់ទំនង ការគ្រប់គ្រងរដ្ឋបាល ការបណ្តុះបណ្តាលគ្រូបង្គោល ការសរសេររបាយការណ៍ និងការគ្រប់គ្រងទំនាស់។ លោកស្រី បានធ្វើការជាមួយសីលការតាំងពីឆ្នាំ ១៩៩៧ មក។ លោកស្រីបានអភិវឌ្ឍកម្មសិក្សាជំនាញឯកទេស និងរៀបចំតាក់តែងវគ្គ ស្តីពីការទំនាក់ទំនង វិធីសាស្ត្របណ្តុះបណ្តាល និងផែនការបណ្តុះបណ្តាល ព្រមទាំងការដោះស្រាយទំនាស់។ ពីមុនលោកស្រី ហុង សុវណ្ណនី ជាអ្នកសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍសៀវភៅ និងកម្មវិធីសិក្សាមុខវិជ្ជាជីវវិទ្យាសំរាប់កំរិតអនុវិទ្យាល័យ ពីឆ្នាំ ១៩៩៤-១៩៩៩។ លោកស្រី សុវណ្ណនី ជាសាស្ត្រាចារ្យជីវវិទ្យា នៅវិទ្យាល័យបឹងត្របែក។ លោកស្រីមានបរិញ្ញាបត្រផ្នែកជីវវិទ្យា ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ លោកស្រីបានទទួលការហ្វឹកហាត់បន្ថែមលើការបណ្តុះបណ្តាលគ្រូបង្គោល និងការងារគ្រប់គ្រង ពី INWENT ប្រទេសអាល្លឺម៉ង់ឆ្នាំ២០០៣ និង២០០៨។

លោកស្រី កាន់មុខងារសំខាន់ក្នុងការបើកវគ្គបណ្តុះបណ្តាលដែល មានកិច្ចសហប្រតិបត្តិការ ជាមួយក្រសួងធនធានទឹក។ លោកស្រីបានកសាងជំនាញបន្ថែមទៀតលើឯកទេសយែនឌ័រ ទំនាក់ទំនង ការសន្ទនា និងការកសាងឯកភាព (កុងសង់ស៊ុស) ព្រមទាំងជំនាញដោះស្រាយទំនាស់។

## លោកស្រី អ៊ូម បូរ៉ានី

លោកស្រី អ៊ូម បូរ៉ានី បានបញ្ចប់បរិញ្ញាបត្រផ្នែកគ្រប់គ្រងគំរោង និងកម្មវិធីអភិវឌ្ឍន៍ និងថ្នាក់អនុ បណ្ឌិតគ្រប់គ្រងនៅសាកលវិទ្យាល័យ Build Bright University (BBU) ។ លោកស្រី ក៏បានទទួល វិញ្ញាប័នបត្រជាន់ខ្ពស់ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ នៅអង្គការយុវជនស្ម័គ្រចិត្តកម្ពុជា ។ លោកស្រីចូលរួមក្នុង ផ្នែកបណ្តុះបណ្តាល លើភាពជាអ្នកដឹកនាំ និងការនិយាយជាសាធារណៈ នៅសាកលវិទ្យាល័យមូលដ្ឋាន។ លោកស្រីមានបទពិសោធន៍ជាជំនួយការប្រធានសម្របសម្រួលគំរោង ក្នុងការអនុវត្តកម្មវិធីសកម្មភាពនៃគំរោង បង្ការហីវ/ជំងឺអេដស៍ នៅអង្គការគាំទ្រកុមារ និងមនុស្សក្មេង។ លោកស្រី បូរ៉ានី បាននាំយកនូវជំនាញធនធានមនុស្ស មកក្នុងសីលការនាឆ្នាំ ២០០៥ ក្នុងការគាំទ្របុគ្គលិក របស់សីលការដើម្បីប្រមូលពតិមាន ពីបុគ្គលិក ក្រសួងកិច្ចការនារី និងបានអភិវឌ្ឍបរិយាយការងារឱ្យសមស្របតាមអាណត្តិថ្មីរបស់ក្រសួង។ លោកស្រីជា សមាជិកសកម្មម្នាក់នៃផ្នែកបណ្តុះបណ្តាលជំនាញរៀបចំគំរោង ជំនាញតាមដាន និងវាយតំលៃ ជំនាញសរសេរសំណើរ និងជំនាញបញ្ជ្រាបយែនឌ័រ។

## លោក គ្រី សុភាព

លោក គ្រី សុភាព បានអនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម (MBA) លោកជាសាស្ត្រាចារ្យ ពេញដោយបទពិសោធន៍ការងារច្រើនបែបយ៉ាង ទាំងជាមួយអង្គការមិនមែនរដ្ឋាភិបាល ទាំងជាមួយស្ថាប័នមូលដ្ឋាន និងជាមួយរដ្ឋាភិបាល។ នៅឆ្នាំ ១៩៩១ លោកមានមុខតំណែងជាប្រធានរដ្ឋបាលនៅមជ្ឍមណ្ឌលបច្ចេកទេសនៅតាមព្រំដែនថៃ។ ក្រោយមកបន្តទៅកាន់មុខងារជាច្រើនទៀត រួមទាំង ការបកប្រែសម័យអន្តរកាល UNTAC និងជាអនុប្រធានរដ្ឋបាល ក្រសួងអភិវឌ្ឍន៍ជនបទ។ លោកក៏មានបទពិសោធន៍ជាប្រធានគ្រប់គ្រងគំរោង ស្រាវជ្រាវទិន្នន័យជនកម្ពុជារងគ្រោះដោយសារមីន។ បន្ទាប់មកលោកធ្វើជាមន្ត្រីតាមដាន និងវាយតំលៃនៅគំរោងសុខភាពទីក្រុងភ្នំពេញ កម្ពុជា។ ជាសន្ទឹម២ លោកសុភាពបានវិលត្រលប់មកផ្នែក អង្គការមិនមែនរដ្ឋាភិបាលវិញ ដោយកាន់មុខងារជាគ្រូហ្វឹកហ្វឺនការងារគ្រប់គ្រង នៅ VBNK។ តាំងពីចូលមកសីលការនាដើមឆ្នាំ២០០៧ លោកចូលរួមយ៉ាងសកម្មក្នុងគំរោងសំខាន់ៗ។ បច្ចុប្បន្នលោកកំពុងនឹងរៀប ចំដំណាក់កាលទី២នៃ គំរោងលើកកំពស់សមត្ថភាពទទួលខុសត្រូវសង្គម (PECSA) តាមគំនិតផ្តួចផ្តើមរបស់ ធនាគារ

ពិភពលោក (WB) ដើម្បីកសាងសមត្ថភាពរបស់សង្គមស៊ីវិលក្នុងការទទួលខុសត្រូវសង្គម និងទាមទារឱ្យមានអភិបាលកិច្ចល្អ។ លើសពីនេះ លោកសុភាពជាសមាជិកសកម្មផ្នែកបណ្តុះបណ្តាលនៃសីលការ ហើយក៏ជាសាស្ត្រាចារ្យ ជាន់ខ្ពស់មួយរូប។

## កញ្ញា ចាន់ សិរី

កញ្ញា ចាន់ សិរី បានចូលរួមជាមួយសីលការ នៅពាក់កណ្តាលឆ្នាំ ២០០៨ ជាគ្រូផ្នែកហិរញ្ញវត្ថុ/គ្រប់គ្រង។ សិរី បានបញ្ចប់សិក្សាជាមួយក៏រិតភាសាអង់គ្លេសខ្ពស់ នៅសាកលវិទ្យាល័យកម្ពុជា តាមកម្មវិធី Fast Track ។ំនទីងមក សីលការ សិរី ធ្វើការជាជំនួយការរដ្ឋបាលផ្ទាល់ នៅអង្គការ LWF ។ កញ្ញាមានបទពិសោធន៏ ពីការងារនៅ LWF ទាំងការងាររៀបចំផែនការគំរោង និងការអនុវត្ត ទាំងការស្រាវជ្រាវគំរោង និងកិច្ចការរដ្ឋបាល។

## លោក កែវ សំអុន

លោក កែវ សំអុន បញ្ចប់ក៏រិតអនុបណ្ឌិតហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង (NUM) នាឆ្នាំ២០០៧ ព្រមទាំងទទួលបរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ ពី NUM ដែរនៅឆ្នាំ២០០៥។ លោកមានបរិញ្ញាបត្ររងភាសាអេស្បាញ នៅសាធារណៈរដ្ឋគុយបា។ លោក កែវ សំអុន បានចាប់ផ្តើមមុខវិជ្ជាជីវៈរបស់លោក ជាជំនួយការមន្ត្រីរដ្ឋបាល/ហិរញ្ញវត្ថុ និងលទ្ធកម្ម ហើយផ្លាស់ធ្វើជាអនុប្រធានការិយាល័យសហប្រតិបត្តិការអន្តរជាតិ។ មុននឹងចូលរួមសីលការ លោក កែវ សំអុន ធ្វើជាសាស្ត្រាចារ្យភាសាអង់គ្លេស នៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ និងជាសមាជិកក្រុមការងារនៃមន្ត្រីគណនេយ្យ និងហិរញ្ញវត្ថុ។ លោកសាស្ត្រាចារ្យចូលរួមជាមួយសីលការជាគ្រូបណ្តុះបណ្តាលជំនាញគ្រប់គ្រងហិរញ្ញវត្ថុ នៅឆ្នាំ២០០៨។